**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីអំពាវនាវ

អនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីសម្ព័ន្ធមេត្រីភាពរវាងកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួង ក៏ដូចជាភ្នាក់ងារជ្រើសរើសឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរឹតចំណងសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចអន្តរាគមន៍លេខ០៧ ដែលកំពុងឈរជើងការពារតាមតំបន់ព្រំដែនខេត្តព្រះវិហារ ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនេះ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** នឹងដឹកនាំប្រតិភូ ចុះសួរសុខទុក្ខ និងរៀបចំពិធីសំណេះសំណាលជាមួយបងប្អូន និងគ្រួសារយុទ្ធជន នៅថ្ងៃព្រហស្បតិ៍ ទី១៤ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៨.៣០នាទីព្រឹក នៅទីបញ្ជាការកងពល ស្ថិតនៅក្នុងភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

ក្នុងស្មារតីនេះ ក្រសួងសូមអំពាវនាវដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ មេត្តាជួយឧបត្ថម្ភនូវថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគនានាតាមសទ្ធាជ្រះថ្លា ដើម្បីលើកទឹកចិត្ត និងគាំទ្រដល់ស្មារតីក្លាហានស្នេហាជាតិរបស់បងប្អូនកងទ័ពយើង។

ក្រសួងសង្ឃឹមជឿជាក់ថា **ឯកឧត្តម លោកជំទាវ លោក លោកស្រី** នឹងចូលរួមគាំទ្រសកម្មភាពនេះ ដើម្បីរួមចំណែកជាមួយកងពលខាងលើឱ្យបានច្រើនកុះករ។

<u>បញ្ជាក់</u>៖ - រសៀលថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ចេញដំណើរដោយមធ្យោបាយផ្ទាល់ខ្លួន។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

<u>សូមទំនាក់ទំនងខុទ្ទកាល័យ</u>

-លោក ង៉ុយ រិទ្ធ ០១២ ៨៥៥ ០៧៥

-លោក ទៀវ ម៉ាក់តែល ០១២ ៨២៣ ៣៧៥

-លោក អ៊ូច ពិសី ០១៦ ៩០២ ៩០៤

-លោកស្រី ជា សុខេន ០៧៧ ៧០០ ៧២៦